# គុណសម្បត្តិនិងគុណវិបត្តិក្នុងការប្រើវិធីសាស្ត្របង្រៀនបញ្ច្រាស់ (Flipped Classroom) ក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស

**ឆោម ជុំរ៉ុង** (កក្កដា ២០២៣)
**មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ**
**លេខទូរស័ព្ទ៖ ០១៧ ៥៥ ៨៨ ៩៨ / ០៦៩ ៥៥ ៨៨ ៩៨**
**អ៊ីម៉េល៖** chhom.chumrong@gmail.com

## ខ្លឹមសារសង្ខេប

ឯកសារនេះមានគោលបំណងបង្ហាញអំពីផលប្រយោជន៍និងបញ្ហាប្រឈម នៅក្នុងការប្រើវិធីសាស្ត្របង្រៀនបញ្ច្រាស់ដែលជាវិធីសាស្ត្រដ៏ពេញនិយមមួយក្នុងសតវត្សរ៍ទី២១ ដើម្បីបង្រៀនភាសាអង់គ្លេសជាភាសាបរទេសឬជាភាសាទីពីរ។ តាមរយៈការធ្វើសំយោគបណ្ណាល័យសាស្ត្រពីអត្ថបទស្រាវជ្រាវជាច្រើនបានបង្ហាញថាវិធីសាស្ត្របង្រៀនបញ្ច្រាស់មានគុណសម្បត្តិខ្លាំងជាងគុណវិបត្តិសម្រាប់ការបង្រៀននិងការរៀនភាសាអង់គ្លេស ដូចជាលើកកម្ពស់ការរៀនជាលក្ខណៈបុគ្គល ការរៀនដោយសកម្ម មានភាពបត់បែន និងផ្តល់ឱកាសពិភាក្សាបានច្រើននិងការគ្រប់គ្រប់ពេលវេលាបានល្អប្រសើរ។ ទោះបីជាមានផលវិជ្ជមានច្រើនយ៉ាងណាក្តី វិធីសាស្ត្របង្រៀនបញ្ច្រាស់ក៏បង្កបញ្ហាប្រឈមពាក់ព័ន្ធនឹងតម្រូវការបច្ចេកវិទ្យា ទំនួលខុសត្រូវខ្ពស់របស់សិស្ស និងពេលវេលារៀបចំមេរៀនរបស់គ្រូបង្រៀនផងដែរ។ ដូច្នេះ លទ្ធផលពីការធ្វើសំយោគបណ្ណាល័យសាស្ត្រនេះអាចផ្តល់ជាធាតុចូលដែលមានសារៈសំខាន់យ៉ាងខ្លាំងដល់គ្រូបង្រៀនឬអ្នកអប់រំនានាដើម្បីទទួលបានការយល់ដឹងបន្ថែមឱ្យកាន់តែស៊ីជម្រៅ ដើម្បីពិចារណាអនុវត្តវិធីសាស្ត្របង្រៀនបែបបញ្ច្រាស់នេះលើការសិក្សារបស់សិស្សនិងនិស្សិតរបស់ខ្លួន។

**ពាក្យគន្លឹះ៖** វិធីសាស្ត្របង្រៀនបញ្ច្រាស់ (flipped classroom) ភាសាអង់គ្លេសជាភាសាបរទេស (EFL) ភាសាអង់គ្លេសជាភាសាទីពីរ (ESL) គុណសម្បត្តិ និងគុណវិបត្តិ

## ១. សេចក្តីផ្តើម

នៅក្នុងសតវត្សរ៍ទី២១ មានវិធីសាស្ត្របង្រៀនទំនើបថ្មីៗជាច្រើនត្រូវបានបង្កើតឡើងដើម្បីសម្រួលការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព។ ចរិកលក្ខណៈនៃវិធីសាស្ត្របង្រៀនទំនើបគឺជាលក្ខណៈសិស្សមជ្ឈមណ្ឌល ផ្អែកលើកិច្ចការឬសកម្មភាព មានប្រភពធនធាន មានសភាពអន្តរកម្ម មានលក្ខណៈសមាហរណកម្ម ព្រមទាំងកិច្ចសហប្រតិបត្តិការជាចក្រុម។ វិធីសាស្ត្របង្រៀនទំនើបរួមមានការរៀនបែបសហប្រតិបត្តិការ (Collaborative Learning) ការរៀនដោយទុកពេលឱ្យគ្រប់គ្រាន់ (Spaced Learning) វិធីសាស្ត្របង្រៀនបញ្ច្រាស់ (Flipped Classroom) ការរៀនដោយស្វ័យត (Self-learning) ការរៀនចេញពីល្បែងកំសាន្ត (Gamification) ការបង្រៀនតាមរយៈរូបភាព សម្លេង និងចលនា (VAK Teaching) ការប្រើប្រាស់បរិស្ថានបង្រៀននិងរៀនទាំងផ្លូវការនិងមិនផ្លូវការ (Crossover Learning) ការរៀនធ្វើគម្រោង (Project-based Learning) ការរៀនដោះស្រាយបញ្ហា (Problem-based Learning) ការរៀនតាក់តែងគំនិតនវានុវត្តន៍ (Design Thinking) និងការរៀនដោយផ្អែកលើគំនិត (Thinking-based Learning) (Mehta, 2023)។

ក្នុងចំណោមវិធីសាស្ត្រខាងលើ វិធីសាស្ត្របង្រៀនបញ្ច្រាស់គឺជាវិធីសាស្ត្រដែលគេនិយមទទួលយកដោយសារវិធីសាស្ត្រនេះបានបង្ហាញថាមានផលិតភាពនិងប្រសិទ្ធភាពដ៏មិនគួរឱ្យជឿសម្រាប់ការអភិវឌ្ឍរបស់សិស្ស។ វិធីសាស្ត្របង្រៀនបញ្ច្រាស់គឺជាវិធីសាស្ត្រគរុកោសល្យមួយដែលការបង្ហាត់បង្រៀនដោយគ្រូផ្ទាល់ក្នុងថ្នាក់រៀនជាក្រុមផ្ទេរទៅរកកន្លែងរៀនលក្ខណៈបុគ្គលវិញ ហើយទីកន្លែងរៀនសូត្រជាក្រុមត្រូវបានផ្លាស់ប្តូរទៅជាបរិស្ថានរៀនសូត្រប្រកបដោយអន្តរកម្មនិងថាមវន្តដែលគ្រូបង្រៀនដើរតួជាអ្នកណែនាំសិស្ស ខណៈពេលដែលសិស្សអនុវត្តនិងចូលរួមយ៉ាងសកម្មក្នុងប្រធានបទដែលរៀនសូត្រ។ គំនិតក្នុងការបង្កើតវិធីសាស្ត្របង្រៀនបញ្ច្រាស់នេះគឺត្រូវបានណែនាំដំបូងដោយលោក ចូណាថាន់ ប៊ឺតម៉ាន (Jonathan Bergmann) និងលោក អារ៉ុន សេមស៍ (Aron Sams) ដែលជាគ្រូប្រង្រៀនគីមីវិទ្យានៅវិទ្យាល័យក្នុងរដ្ឋកូឡូរ៉ាដូ សហរដ្ឋអាម៉េរិក នៅពេលលោកគ្រូទាំងពីរបានចាប់ផ្តើមថតទុកមេរៀនរបស់ពួកគាត់ក្នុងឆ្នាំ២០០៧ (Michigan State University, n.d)។

ជាទ្រឹស្តី វិធីសាស្ត្របង្រៀនបញ្ច្រាស់មានគោលបំណងធ្វើឱ្យប្រសើរលទ្ធផលសិក្សានិងជំនាញអាចប្រើការបានប៉ុណ្ណោះទេ ប៉ុន្តែនៅពេលដំណាលគ្នាក៏មានគោលបំណងគាំទ្រស្វយ័តភាពរបស់អ្នករៀន តាមរយៈការផ្តល់ទំនួលខុសត្រូវបន្ថែមលើសិស្សសម្រាប់ដំណើរការរៀនសូត្ររបស់ពួកគេផ្ទាល់ ជំរុញនិងបង្កើនអារម្មណ៍ការសម្រេចដោយផ្ទាល់ខ្លួននិងភាពជោគជ័យ ព្រមទាំងលើកកម្ពស់កម្លាំងចិត្តជាទូទៅរបស់អ្នករៀនផងដែរ (Bergmann & Sams, 2012)។

នៅពេលដំបូងលោក ចូណាថាន់ និងអារ៉ុន គ្រាន់តែព្យាយាមធ្វើឱ្យមេរៀនគីមីវិទ្យារបស់ពួកគាត់ អាចឱ្យសិស្សជាច្រើនទទួលបានជាពិសេសមានបំណងផ្តោតលើសិស្សដែលមានអត្រាវត្តមាននៅសាលារៀនកម្រិតទាប។ ពួកគាត់បានបង្កើតវិធីសាស្ត្របង្រៀនប្រកបដោយនវានុវត្តន៍របស់ពួកគាត់ផ្ទាល់ ហើយជាលទ្ធផលពួកគាត់មិនត្រឹមតែសម្រេចបានជោគជ័យនៅក្នុងថ្នាក់រៀនផ្ទាល់របស់ពួកគាត់ប៉ុណ្ណោះទេ វីដេអូដែលពួកគាត់បានផលិតក៏មានប្រជាប្រិយភាពខ្លាំងក្នុងចំណោមមនុស្សម្នាមកពីខាងក្រៅថ្នាក់និងសាលារៀនថែមទៀតផងដែរ (Bergmann & Sams, 2012)។

គំរូវិធីសាស្ត្របង្រៀនបញ្ច្រាស់នេះផ្គួបការរៀនទាំងអនឡាញនិងមិនអនឡាញដោយបញ្ចូលសកម្មភាពរៀនជាលក្ខណៈបុគ្គលនិងការធ្វើអន្តរកម្មទល់មុខគ្នាផ្ទាល់។ នៅក្នុងដំណាក់កាលរៀនជាលក្ខណៈបុគ្គល សិស្សអាចមើលវីដេអូនិងអានឯកសាររៀនរបស់វគ្គសិក្សានៅផ្ទះតាមជំហ៊ានរបស់ពួកគេផ្ទាល់ ហើយពេលនៅក្នុងថ្នាក់សិស្សចូលរួមក្នុងសកម្មភាពដែលមានការរៀបចំ ដើម្បីធ្វើឱ្យការយល់ដឹងរបស់ពួកគេកាន់តែស៊ីជម្រៅថែមទៀតពីឯកសារមេរៀនក្នុងវគ្គសិក្សា (Martin, 2022)។

នៅក្នុងវិធីសាស្ត្របង្រៀនបញ្ច្រាស់មានភាពពាក់ព័ន្ធនឹងតារាងវិជ្ជានុក្រមប្លូម (Bloom Taxonomy) សិស្សត្រូវមានទំនួលខុសត្រូវក្នុងការរៀនសូត្ររបស់ខ្លួន ដូច្នេះតារាងវិជ្ជានុក្រមប្លូមត្រូវបានត្រឡប់ចុះក្រោមវិញដែលសិស្សត្រូវអនុវត្តការចងចាំ ការយល់ និងការអនុវត្ត ដែលទាក់ទិននឹងជំនាញគិតលំដាប់ទាប(LOTS)[១] នៅផ្ទះ តាមរយៈការមើលវីដេអូការចូលមើលគេហទំព័រពាក់ព័ន្ធនឹងវគ្គសិក្សា ការស្តាប់សម្លេងថត ឬការអានមេរៀនជាដើម។ ពេលនៅក្នុងថ្នាក់រៀន គ្រូបង្រៀនជួយឱ្យសិស្សធ្វើការវិភាគ ការវាយតម្លៃ និងការបង្កើតចំណេះដឹងថ្មីតាមការគ្រោងទុក។ ដូច្នេះគ្រូបង្រៀនចំណាយពេលក្នុងថ្នាក់រៀនដ៏មានតម្លៃជាមួយសិស្ស ដោយធ្វើឱ្យសិស្សចូលរួមក្នុងសកម្មភាពនានាដែលត្រូវការជំនាញគិតលំដាប់ខ្ពស់(HOTS)[២] និងជួយសម្របសម្រួលការរៀនកាន់តែស៊ីជម្រៅ (Bergmann & Sams, 2014)។

---

[១] LOTS: Low-Order Thinking Skills (Remembering, Understanding, Applying)

[២] HOTS: High-Order Thinking Skills (Analyzing, Evaluating, Creating)

វិធីសាស្រ្តបង្រៀនបញ្ច្រាស់មានសសរស្តម្ភចំនួន ៤ (FLIP)៖ ទីមួយ បរិស្ថានដែលមានភាពបត់បែន(Flexible Environment) ដែលសិស្សមានស្វយ័តភាពច្រើនដើម្បីជ្រើសរើសនូវអ្វីនិងពេលណាដែលពួកគាត់ចង់រៀនសូត្រ ទីពីរ វប្បធម៌រៀនសូត្រ(Learning Culture) ដែលផ្លាស់ប្តូរពីតួនាទីគ្រូជាប្រភពចម្បងនៃព័ត៌មានទៅប្រើប្រាស់ពេលវេលាបង្កើតឱកាសរៀនសូត្រ និងជួយសិស្សស្វែងយល់ពីប្រធានបទនានាឱ្យកាន់តែស៊ីជម្រៅក្នុងម៉ោងរៀនក្នុងថ្នាក់ ទីបី មាតិកាមានគោលបំណងច្បាស់លាស់(Intentional Content) ដែលគ្រូកំណត់នូវអ្វីដែលត្រូវការបង្រៀនព្រមទាំងឯកសារនិងមាតិកាអ្វីដែលសិស្សគួរស្វែងយល់ដោយឯករាជ្យបាន និងទីបួន អ្នកអប់រំប្រកបដោយវិជ្ជាជីវៈ (Professional Educator) ដែលអ្នកអប់រំប្រកាន់យកវិធីសាស្រ្តអនុវត្តផ្ទាល់ច្រើននិងបើកចំហសម្រាប់ការរិះគន់ស្ថាបនានិងធ្វើការឆ្លុះបញ្ចាំងព្រមទាំងកែសម្រួលការបង្រៀនរបស់ពួកគាត់(The Four Pillars of Flipped Learning, 2017)។

## ២. ការប្រើវិធីសាស្រ្តបង្រៀនបញ្ច្រាស់

សម្រាប់ការប្រើវិធីសាស្រ្តបង្រៀនបញ្ច្រាស់នេះលោក ចេហ្វ្រី ឌុន(Jeffrey Dunn) បានបង្ហាញជំហានងាយស្រួលចំនួន ៦៖ (១)រៀបចំផែនការ (២)ថតទុក (៣)ចែករម្លែក (៤)ផ្លាស់ប្តូរ (៥)រៀបចំក្រុម និង(៦)ផ្លាស់ក្រុម (Dunn, 2014)។

យោងតាម Fielden et al (2020) វិធីសាស្រ្តបង្រៀនបញ្ច្រាស់នេះបានលូតលាស់ចេញពីគំរូចាស់ៗព្រមទាំងពីភាពជឿនលឿននៃការស្រាវជ្រាវផ្នែកចិត្តសាស្រ្តពាក់ព័ន្ធនឹងការអប់រំដូចជា ការរៀនសកម្ម (active learning) ការរៀនតាមបែបសិស្សមជ្ឈមណ្ឌល(student-centered learning) ការរៀនភាសាតាមលក្ខណៈទំនាក់ទំនង (communicative language learning) និងការរៀនបែបចម្រុះ(blended learning)ជាដើម។ ជាងនេះទៀតផលប្រយោជន៍ធំជាងគេក្នុងការប្រើវិធីសាស្រ្តបញ្ច្រាស់នៅក្នុងថ្នាក់រៀនភាសាបរទេស ទីមួយ កម្លាំងចិត្តដល់អ្នករៀនសូត្រ និងទីពីរ ការលើកកម្ពស់ជំនាញដូចជាការអាន ការសរសេរ ការនិយាយ ការស្តាប់ និងវេយ្យាករណ៍ជាដើម។ ជាសេចក្តីណែនាំនៅក្នុងការប្រើប្រាស់វិធីសាស្រ្តនេះវិញ ទីមួយ វិធីសាស្រ្តបង្រៀនបញ្ច្រាស់អាចប្រើប្រាស់ជាយន្តការមួយសម្រាប់ការរក្សាជំហានផ្ទាល់ខ្លួនសម្រាប់សិស្សរៀនភាសាបរទេស ទីពីរ អាចពន្លឿនជំនាញរៀនសូត្រលំដាប់ខ្ពស់លើភាសាបរទេស ទីបី អាចបន្ថែមចំណេះដឹងរបស់សិស្សតាមរយៈការរៀនចំទុកជាមុន ទីបួន អាចដោះស្រាយជំនាញភាសាបរទេសអសកម្មផ្សេងៗដែលយើងជារឿយៗមិនយកចិត្តទុកដាក់ដូចជានៅក្នុងការស្តាប់និងការអាន ទីប្រាំ អាចនាំសិស្សចូលរួមសរសេរយ៉ាងសកម្ម ទីប្រាំមួយ អាចផ្លាស់ប្តូរពីការរៀនតាមការទន្ទេញចាំមាត់ចេញពីថ្នាក់រៀន ទីប្រាំពីរ អាចបង្កើតអន្តរកម្មនិងធ្វើការសង្កេតមើលបានច្រើនដោយសារសិស្សមានពេលច្រើនដើម្បីធ្វើទំនាក់ទំនង ទីប្រាំបី អាចដឹងពីតម្រូវការជារចនាសម្ព័ន្ធ និងទីប្រាំបួន អាចចូលរួមទំនាក់ទំនាក់ពិតប្រាកដកាន់តែជិតស្និទជាមួយការធ្វើឧទ្ទេសកាន់តែតិច។

លក្ខណៈខុសគ្នាចម្បងរវាងថ្នាក់រៀនតាមបែបប្រពៃណីនិងថ្នាក់រៀនបែបបញ្ច្រាស់មានបង្ហាញដូចក្នុងតារាងខាងក្រោម៖

| | **ថ្នាក់រៀនបែបប្រពៃណី** | **ថ្នាក់រៀនបែបបញ្ច្រាស់** |
|---|---|---|
| **តួនាទីគ្រូបង្រៀន** | ជាអ្នកមានចំណេះដឹងនិងគ្រប់គ្រងថ្នាក់ | ជាអ្នកបង្ហាត់និងអ្នកជំរុញ |
| **តួនាទីសិស្ស** | អ្នករៀនអកម្ម | អ្នករៀនសកម្មនិងអ្នកស្រាវជ្រាវ |
| **វិធីសាស្រ្តបង្រៀននៅក្នុងថ្នាក់** | ការបង្រៀននៅក្នុងថ្នាក់និងធ្វើកិច្ចការផ្ទះបន្ទាប់ចេញពីរៀន | ការរៀនជាមុនមុនមកថ្នាក់និងពិភាក្សាពីបញ្ហានៅក្នុងថ្នាក់ |

| | | |
|---|---|---|
| **របាយពេលវេលានៅក្នុងថ្នាក់** | ចំណាយពេលភាគច្រើនក្នុងការបង្រៀន | ចំណាយពេលភាគច្រើនក្នុងការពិភាក្សាក្នុងចំណោមសិស្ស |
| **មាតិកាបង្រៀននៅក្នុងថ្នាក់** | ការបង្រៀននិងការចែករម្លែកចំណេះដឹង | ការរៀនមានជាសំណួរ-ចម្លើយ |
| **ការប្រើប្រាស់វិធីសាស្ត្របង្រៀន** | ការធ្វើឧទ្ទេសពីមាតិកាមេរៀនសូត្រ | ការរៀនដោយស្វយ័តនិងការរៀនក្នុងលក្ខណៈសហការ |
| **ការវាយតម្លៃការបង្រៀន** | តេស្តសរសេរលើក្រដាស | ការវាយតម្លៃពីទិដ្ឋភាពចម្រុះ |

ប្រភព៖ (Renxian, 2014 as cited in Deng, 2019)

ដើម្បីអនុវត្តដំណើរការវិធីសាស្ត្របង្រៀនបញ្ច្រាស់ឱ្យមានប្រសិទ្ធភាព Mulawarman et al (2020) បានលើកជាបីដំណាក់កាលដែលគ្រូបង្រៀនត្រូវអនុវត្ត៖ ការរៀបចំផែនការ ការអនុវត្ត និងការវាយតម្លៃ។ អំឡុងដំណាក់កាលរៀបចំផែនការ គ្រូបង្រៀនត្រូវចាត់ចែងនិងរៀបចំផែនការសម្រាប់សកម្មភាពដែលនឹងត្រូវអនុវត្តក្នុងថ្នាក់រៀនបែបបញ្ច្រាស់។ នៅក្នុងដំណាក់កាលអនុវត្ត គ្រូបង្រៀនផ្តល់មាតិកាមេរៀនដល់សិស្សមុនចូលរៀននិងអំឡុងសកម្មភាពក្នុងថ្នាក់ ហើយមានវិធីសាស្ត្រមួយចំនួនដែលសម្របសម្រួលវិធីសាស្ត្របង្រៀនបញ្ច្រាស់បាន ដូចជាការរៀនធ្វើគម្រោងដែលសិស្សធ្វើការរុករក ការវាយតម្លៃ និងការធ្វើសំយោគព័ត៌មានដើម្បីទទួលបានចំណេះដឹង ជំនាញ និងឥរិយាបថ។ វិធីសាស្ត្រមួយទៀតអាចជាការពិភាក្សាជាក្រុម ដែលសិស្សចែករំលែកបទពិសោធន៍និងចំណេះដឹងដូច្នេះពួកគេអាចបង្កើតអត្ថន័យនិងសម្រេចគោលដៅនៃការបង្រៀន។ នៅក្នុងដំណាក់កាលវាយតម្លៃនិងតាមដាន គ្រូបង្រៀនត្រូវវាយតម្លៃគ្រប់ផែនការនិងសកម្មភាពទាំងអស់ ដើម្បីធ្វើឱ្យប្រាកដថាវិធីសាស្ត្របង្រៀនបញ្ច្រាស់បានសម្រេចគោលដៅនិងដើម្បីកែតម្រូវភាពខ្វះខាតណាមួយដែលកើតឡើងអំឡុងពេលដំណើរការ។ តាមរយៈធាតុចូលដូចជាវត្តមាន សកម្មភាពតាមអនឡាញ និងលទ្ធផលវាយតម្លៃ និងធាតុចេញឬលទ្ធផល រួមមានការផ្លាស់ប្តូរឥរិយាបថ ការអភិវឌ្ឍជំនាញផ្សេងៗ និងចំណេះដឹងកើនឡើងជាងមុន ចំណុចទាំងអស់នេះជាសូចនករនៃភាពជោគជ័យរបស់វិធីសាស្ត្របង្រៀនបញ្ច្រាស់។

ការប្រើប្រាស់វិធីសាស្ត្របង្រៀនបញ្ច្រាស់សម្រាប់គោលបំណងបង្រៀននិងរៀនភាសាជាទូទៅ ជាពិសេសការបង្រៀនភាសាអង់គ្លេសជាភាសាបរទេសឬភាសាទីពីរ ក៏មានការសិក្សាស្រាវជ្រាវជាច្រើនផងដែរដែលបានរកឃើញទាំងគុណសម្បត្តិនិងគុណវិបត្តិ។ ហេតុដូចនេះគោលបំណងនៃការសិក្សានេះ គឺដើម្បីពិភាក្សាអំពីផលប្រយោជន៍និងបញ្ហាប្រឈម ក្នុងការប្រើវិធីសាស្ត្របង្រៀនបញ្ច្រាស់ដើម្បីបង្រៀនភាសាអង់គ្លេសជាភាសាបរទេសឬជាភាសាទីពីរតាមរយៈការធ្វើសំយោគបណ្ណាល័យសាស្ត្រ ដែលមានសារៈសំខាន់សម្រាប់គ្រូបង្រៀនឬអ្នកអប់រំនានាទទួលបានការយល់ដឹងបន្ថែមឱ្យកាន់តែស៊ីជម្រៅថាតើការអនុវត្តវិធីសាស្ត្រនេះមានគុណសម្បត្តិនិងគុណវិបត្តិយ៉ាងណាខ្លះក្នុងការយកចំពោះការសិក្សារបស់សិស្សនិងនិស្សិតរបស់ខ្លួន។

# ៣. គុណសម្បត្តិនិងគុណវិបត្តិរបស់វិធីសាស្ត្របង្រៀនបញ្ច្រាស់

## ៣.១ គុណសម្បត្តិរបស់វិធីសាស្ត្របង្រៀនបញ្ច្រាស់

មានការសិក្សាជាច្រើនទាក់ទិននឹងវិធីសាស្ត្របង្រៀនបញ្ច្រាស់ និងបានរកឃើញផលប៉ះពាល់វិជ្ជមាននៅក្នុងដំណើរការបង្រៀននិងរៀនភាសាអង់គ្លេសជាភាសាបរទេសឬភាសាទីពីរដូចជាការសិក្សាលើទស្សនៈរបស់សិស្សភាសាអង់គ្លេសលើការអនុវត្តវិធីសាស្ត្របង្រៀនបញ្ច្រាស់របស់ Doman & Webb, 2017; Fauzan & Ngabut, 2018 និង Alghasab, 2020 ដែលលទ្ធផលបង្ហាញថាសិស្សភាគច្រើនបានផ្តល់មតិវិជ្ជមានចំពោះវិធីសាស្ត្របង្រៀនបញ្ច្រាស់។ នៅក្នុងការសិក្សារបស់ Yang & Chen, 2020; Mahalli et al., 2019 និង Ansori & Nafi, 2018 លើទស្សនៈរបស់គ្រូ

បង្រៀនភាសាអង់គ្លេសក៏បង្ហាញទស្សនៈវិជ្ជមានចំពោះវិធីសាស្ត្របង្រៀនបញ្ច្រាស់ដែលអាចបង្កើតបរិស្ថានរៀនសូត្រដែលសកម្មជាងវិធីសាស្ត្រប្រពៃណី។

Roth & Suppasetseree (2016) ដែលបានសិក្សាពីវិធីសាស្ត្របង្រៀនបញ្ច្រាស់ថាអាចជួយលើកកម្ពស់ការយល់ដឹងក្នុងជំនាញស្តាប់សម្រាប់សិស្សរៀនភាសាអង់គ្លេសជាភាសាបរទេសមុនចូលមហាវិទ្យាល័យ នៅក្នុងប្រទេសកម្ពុជាបានរកឃើញថាសិស្សមានទស្សនៈវិជ្ជមានលើការរៀនភាសាអង់គ្លេសតាមរយៈវិធីសាស្ត្របង្រៀនបញ្ច្រាស់ហើយពួកគេបានគិតថាវិធីសាស្ត្របង្រៀនបញ្ច្រាស់នេះ អាចជួយឱ្យពួកគេមានភាពប្រសើរក្នុងការយល់ដឹងទាក់ទិននឹងការស្តាប់ លើសពីនេះទៀតពួកគេភាគច្រើនក៏ចង់រៀនវគ្គផ្សេងៗទៀតដូចជាគណិតវិទ្យា ភាសាអង់គ្លេស និងទីផ្សារតាមរយៈវិធីសាស្ត្របង្រៀនបញ្ច្រាស់នេះដែរ។

នៅក្នុងការសិក្សារបស់ Phoeun & Sengsri (2021) ដែលពិនិត្យថាតើវិធីសាស្ត្របង្រៀនបញ្ច្រាស់និងការបង្រៀនភាសាតាមបែបទំនាក់ទំនង អាចនាំឱ្យនិស្សិតមានការកើនឡើងលើជំនាញនិយាយនៅក្នុងថ្នាក់ភាសាអង់គ្លេសនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្ហាញថានិស្សិតដែលបានចូលរួមក្នុងការសិក្សាមិនត្រឹមបង្កើនសមត្ថភាពនិយាយរបស់ពួកគេប៉ុណ្ណោះទេថែមទាំងបានផ្លាស់ប្តូរឥរិយាបថរបស់ពួកគេចំពោះការរៀនភាសាអង់គ្លេសទៀតផង។ លទ្ធផលនេះបានគូសបញ្ជាក់ថា វិធីសាស្ត្របង្រៀនបញ្ច្រាស់រួមជាមួយសកម្មភាពវិធីសាស្ត្របង្រៀនភាសាតាមបែបទំនាក់ទំនងមានប្រសិទ្ធភាពក្នុងការលើកកម្ពស់សមត្ថភាពនិយាយរបស់និស្សិតដែលរួមចំណែកយ៉ាងសំខាន់ដល់លទ្ធផលរៀនសូត្រមានភាពល្អប្រសើរ។

Nuon & Champakaew (2017) ដែលបានសិក្សាពីឥទ្ធិពលរបស់ថ្នាក់រៀនបែបបញ្ច្រាស់ដែលមានជំនួយពីបច្ចេកវិទ្យាព័ត៌មាននិងកុំព្យូទ័រលើការចេះដឹងវេយ្យាករណ៍ចំពោះនិស្សិតសកលវិទ្យាល័យចំនួន៨១នាក់នៅក្នុងប្រទេសកម្ពុជា ដោយចែកជាពីរក្រុមមួយក្រុមការបង្រៀនមិនមែនបែបបញ្ច្រាស់និងមួយក្រុមផ្សេងទៀតទទួលការបង្រៀនបែបបញ្ច្រាស់ ជាលទ្ធផលបានបង្ហាញថានិស្សិតទាំងពីរក្រុមចេះវេយ្យាករណ៍បានប្រសើរដូចគ្នា ប៉ុន្តែក្រុមដែលទទួលបានការពិសោធន៍ទទួលបានពិន្ទុខ្ពស់ជាង។ តាមរយៈការចូលរួមមើលវីដេអូនិងឯកសារអានជាមុនអាចនាំឱ្យសមត្ថភាពសិក្សាខ្ពស់ជាង។ ការសិក្សានេះក៏បានផ្តល់ជាយោបល់ដែរថាសកម្មភាពមុនចូលថ្នាក់រៀន សកម្មភាពក្នុងថ្នាក់រៀន និងដំណើរការបង្រៀនគឺជាកត្តាដែលជះឥទ្ធិពលលើការចេះវេយ្យាករណ៍ប្រសើរឡើង។

Abedi et al (2019) ដែលធ្វើការសិក្សាពីការបង្ហាត់ដោយប្រើវិធីសាស្ត្របង្រៀនលើការសរសេរតែងសេចក្តីជាភាសាអង់គ្លេសរបស់និស្សិតជនជាតិអ៊ីរ៉ង់ដែលរៀនភាសាអង់គ្លេសជាភាសាបរទេសនោះ លទ្ធផលបានបង្ហាញថាវិធីសាស្ត្រនេះជាវិធីសាស្ត្រដ៏មានប្រយោជន៍ ដែលអាចពង្រីកជំនាញសរសេរដោយសារនិស្សិតដែលបានបង្រៀនតាមវិធីសាស្ត្របញ្ច្រាស់អាចធ្វើបានដោយជោគជ័យជាងនៅក្នុងការលទ្ធផលក្រោយការធ្វើតេស្តជាងអ្នកដែលត្រូវបានបង្រៀនតាមបែបប្រពៃណី ហើយនិស្សិតបានពេញចិត្តចំពោះសមត្ថភាពដែលពួកគេអាចបំពេញសាច់រឿងតែងសេចក្តីនិងលំហាត់សរសេរបានមុនពេលចូលរៀនក្នុងថ្នាក់។ ការរៀនសូត្ររបស់ពួកគេបានកើតឡើងដោយសារការវិភាគខ្លាំងលើគំនិតសំខាន់ៗតាមជំហ៊ានរបស់ពួកគេផ្ទាល់នៅទីកន្លែងតាមបុគ្គលចង់ដូចជានៅផ្ទះរបស់ពួកគេ។ ការធ្វើបែបនេះពួកគេអាចលើកកម្ពស់ជំនាញសរសេរភាសាអង់គ្លេសរបស់ពួកគេបានដោយការធ្វើតាមយុទ្ធសាស្ត្រដែលបានបង្រៀន។

Kırmızı & Kömeç (2019) បានសិក្សាពីផលប៉ះពាល់របស់វិធីសាស្ត្របង្រៀនបញ្ច្រាស់លើការរៀនវាក្យសព្ទក្នុងជំនាញទទួលនិងផលិតភាព លើសិស្សវិទ្យាល័យចំនួន ៥៨នាក់នៅប្រទេសតួគី ដោយបានធ្វើការពិសោធន៍ការបង្ហាត់តាមវិធីសាស្ត្របង្រៀនបញ្ច្រាស់រយៈពេល៤សប្តាហ៍។ លទ្ធផលបានបង្ហាញថា ការបង្ហាត់តាមវិធីសាស្ត្របង្រៀនបញ្ច្រាស់បានលើកកម្ពស់ការអភិវឌ្ឍវាក្យសព្ទរបស់សិស្សរៀនភាសាអង់គ្លេស ប្រកបដោយប្រសិទ្ធភាពនិងមានសារៈសំខាន់យ៉ាងខ្លាំង ហើយសិស្សដែលទទួលបានការបង្ហាត់វាក្យសព្ទតាមវិធីសាស្ត្របង្រៀនបញ្ច្រាស់ជាទូទៅមាន

ឥរិយាបថវិជ្ជមានចំពោះបរិស្ថាននិងសកម្មភាពរៀនសូត្រ ហើយសិស្សក៏សប្បាយរីករាយការរៀនពីវីដេអូវាក្យស័ព្ទដែលមានភាពរហ័សនិងងាយស្រួលសម្រាប់ពួកគេ។ តាមលទ្ធផលពីកម្រងសំណួរវិញក៏បានបង្ហាញថាសិស្សពេញចិត្តនឹងវិធីសាស្ត្រនេះដោយសារមានពេលច្រើនសម្រាប់សកម្មភាពអនុវត្តបានច្រើននៅក្នុងថ្នាក់រៀន។

Abdullah et al. (2021) ដែលបានធ្វើការសិក្សាពីឥទ្ធិពលនៃការអនុវត្តវិធីសាស្ត្របង្រៀនបញ្ច្រាស់លើទំនុកចិត្តផ្ទាល់ខ្លួនរបស់និស្សិតលើសមត្ថភាពនិយាយភាសាអង់គ្លេស តាមលទ្ធផលវិភាគរបស់ ANOVA និង MANOVA បានបង្ហាញថាការអនុវត្តវិធីសាស្ត្របង្រៀនបញ្ច្រាស់ បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការបង្កើនទំនុកចិត្តផ្ទាល់ខ្លួនរបស់សិស្សលើសមត្ថភាពនិយាយភាសាអង់គ្លេស ដោយសារវិធីសាស្ត្រនេះជួយនិស្សិតមានជំនាញរៀនប្រសើរឡើងនិងជំនះភាពលំបាកក្នុងការរៀនសូត្ររបស់ពួកគេ។ លក្ខណៈបង្ហាត់តាមវិធីសាស្ត្របង្រៀនបញ្ច្រាស់និងសកម្មភាពដែលរៀបចំបានល្អទាំងនៅក្នុងថ្នាក់និងក្រៅថ្នាក់ បានផ្ដល់ឱ្យនិស្សិតនូវឱកាសជាច្រើនដើម្បីលើកកម្ពស់ទំនុកចិត្តផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងបរិស្ថានថ្នាក់រៀនមួយដែលមានភាពច្នៃប្រឌិត មានការចូលរួម មានសុវត្ថិភាព មានផាសុកភាព និងមានការលើកទឹកចិត្ត។

តាមការសិក្សារបស់ Chen Hsieh et al. (2017) លើការប្រើប្រាស់វិធីសាស្ត្របង្រៀនបញ្ច្រាស់ដើម្បីលើកកម្ពស់ការរៀនភាសាអង់គ្លេសជាភាសាបរទេសលើនិស្សិតជំនាញអង់គ្លេសឆ្នាំទី២ចំនួន៤៨នាក់នៅកោះតៃវ៉ាន់ ដោយចែកចេញជាពីរក្រុម៖ មួយក្រុមឱ្យរៀនសំនួនវោហារភាសាអង់គ្លេសតាមរយៈការរៀនបែបបញ្ច្រាស់និងដោយប្រើកម្មវិធីទូរស័ព្ទ «ឡាញ» និងមួយក្រុមទៀតដោយការបង្ហាត់តាមបែបប្រពៃណីផងដែរ។ ដើម្បីទទួលបានលទ្ធផលអ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រស្រាវជ្រាវចម្រុះប្រមូលទិន្នន័យរួមមានការធ្វើតេស្តមុននិងក្រោយលើសំនួនវោហារ មានកម្រងសំណួរពីរ ការអង្កេតក្នុងថ្នាក់រៀន និងការសម្ភាសជាក្រុមពាក់កណ្ដាលគ្រោងទុក លទ្ធផលបានបង្ហាញថាការបង្ហាត់តាមវិធីបង្រៀនបញ្ច្រាស់ផ្អែកលើទ្រឹស្ដីដោយប្រើអន្តរកម្មផ្ទាល់មាត់និងសរសេរ មិនត្រឹមតែជំរុញកម្លាំងចិត្តរបស់អ្នកចូលរួមដោយបានធ្វើឱ្យពួកគេកាន់តែសកម្មក្នុងការប្រើសំនួនវោហារនៅក្នុងថ្នាក់ប៉ុណ្ណោះទេ ថែមទាំងលើកកម្ពស់ចំណេះដឹងសំនួនវោហាររបស់ពួកគេយ៉ាងខ្លាំង ដែលបង្ហាញថាការរៀនតាមវិធីបង្រៀនបញ្ច្រាស់មានភាពជោគជ័យក្នុងការសម្រេចបាននូវគោលដៅបង្រៀននៅក្នុងថ្នាក់។

នៅក្នុងការសិក្សាមួយទៀតរបស់ Alsowat (2016) ដែលផ្ដោតលើឥទ្ធិពលគំរូបង្រៀនភាសាអង់គ្លេសជាភាសាបរទេសតាមវិធីសាស្ត្របញ្ច្រាស់(EFL-FCTM)[៣] លើជំនាញគិតលំដាប់ខ្ពស់ផ្នែកភាសាអង់គ្លេស(HOTS) ការចូលរួមរៀនសូត្រ និងសេចក្ដីពេញចិត្តរបស់និស្សិតចំនួន ៦៧នាក់ ដែលកំពុងរៀនភាសាអង់គ្លេសនៅសកលវិទ្យាល័យ Taif ប្រទេសអារ៉ាប៊ីសាអ៊ូឌីត។ និស្សិតត្រូវបានបែកចែកជាពីរក្រុម៖ មួយក្រុមទទួលការពិសោធន៍ដែលពួកគេត្រូវបានបង្ហាត់តាមវិធីសាស្ត្របង្រៀនបញ្ច្រាស់ និងមួយក្រុមទៀតបង្ហាត់តាមវិធីសាស្ត្រធម្មតា។ តាមរយៈការប្រើវិធីសាស្ត្រចម្រុះ ការធ្វើតេស្ត HOTS មុននិងក្រោយ និងកម្រងសំណួរ លទ្ធផលបានបង្ហាញថាក្រុមដែលទទួលគំរូពិសោធន៍ EFL-FCTM មានភាពខុសគ្នាផ្នែកស្ថិតិខ្លាំង ហើយសេចក្ដីពេញចិត្តលើគំរូក៏មានកម្រិតខ្ពស់ផងដែរ។ គំរូនេះមានប្រសិទ្ធភាពក្នុងការបង្កើនជំនាញគិតលំដាប់ខ្ពស់លើភាសាបរទេស ការចូលរួមរៀនសូត្រ និងសេចក្ដីពេញចិត្តរបស់និស្សិត។ ដូច្នេះការផ្លាស់ប្ដូរពីវិធីសាស្ត្របង្រៀនបែបប្រពៃណីទៅរកវិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាពច្រើនជាងដូចជាវិធីសាស្ត្របង្រៀនបញ្ច្រាស់ ដោយសារសិស្សចូលរួមនៅក្នុងដំណើរការរៀនសូត្រប្រកបដោយអត្ថន័យ ហើយវិធីសាស្ត្រនេះក៏កាត់បន្ថយភារកិច្ចរបស់គ្រូបង្រៀននៅក្នុងការបង្រៀនផងដែរដោយសារសិស្សបានត្រៀមខ្លួនទាំងផ្លូវចិត្តនិងផ្លូវកាយដើម្បីអនុវត្តការរៀនសូត្រ។

[៣] EFL-FCTM: English as a Foreign Language Flipped Classroom Teaching Model

## ៣.២ គុណវិបត្តិរបស់វិធីសាស្ត្របង្រៀនបញ្ច្រាស់

ទោះបីជាវិធីសាស្ត្របង្រៀនបញ្ច្រាស់មានគុណសម្បត្តិជាច្រើន វិធីសាស្ត្របង្រៀនបញ្ច្រាស់ក៏មិនមែនជាវិធីសាស្ត្រងាយស្រួលមួយដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពដែរ ដោយសារគ្រូបង្រៀនត្រូវចំណាយពេលកាន់តែកើនឡើងលើការរៀបចំឯកសារបង្រៀន ខណៈពេលអ្នករៀនសូត្រក៏ត្រូវការមានស្វយ័តភាពនិងទំនួលខុសត្រូវខ្លាំងក្នុងការរៀនសូត្ររបស់ពួកគេផ្ទាល់ផងដែរ (Birová, 2019)។

ស្រដៀងទៅនឹងការសិក្សាខាងលើ Ngo & Yunus (2021) បានលើកឡើងពីកត្តាមួយចំនួនដែលអាចប៉ះពាល់ការអនុវត្តវិធីសាស្ត្របង្រៀនបញ្ច្រាស់ដូចជាសិស្សត្រូវការមានស្វយ័តភាពនៅក្នុងការរៀន ដូច្នេះសិស្សអាចមានបញ្ហានៅក្នុងការសម្របទៅការរៀនតាមវិធីសាស្ត្របញ្ច្រាស់ប្រសិនពួកគេមិនមែនជាសិស្សដែលអាចរៀនដោយស្វយ័ត។ ការរៀនដោយស្វយ័តក៏តម្រូវសិស្សឱ្យមានវិន័យផ្ទាល់ខ្លួនខ្ពស់ផងដែរដែលសិស្សអាចយល់ឃើញថាជាបញ្ហាប្រឈម ដើម្បីមានទំនួលខុសត្រូវរៀនដោយខ្លួនឯងនៅផ្ទះដោយសារមានការរំខានជាច្រើនដែលអាចធ្វើឱ្យពួកគេបាត់ការផ្តោតអារម្មណ៍។ កត្តាមួយទៀតដែលប៉ះពាល់លើវិធីសាស្ត្រនេះគឺហេដ្ឋារចនាសម្ព័ន្ធនិងធនធានបច្ចេកវិទ្យាព័ត៌មានដែលសិស្សត្រូវការមានកុំព្យូទ័រ ឡេបថប់ ធុងបាស់ និងតំណភ្ជាប់អ៊ីនធើណេតខ្លាំង។ សិស្សមួយចំនួនអាចមិនមានសមត្ថភាពមានកុំព្យូទ័រឬឡេបថប់ផ្ទាល់ខ្លួនទេ ហើយបណ្តាញអ៊ីនធើណេតដែលនៅមានកម្រិតក៏អាចប្រឈមបញ្ហាសម្រាប់សិស្សមើលមេរៀនតាមអនឡាញផងដែរ។

នៅក្នុងការសិក្សារបស់ Nuon & Champakaew (2017) បានលើកឡើងពីផលវិបាកមួយចំនួនពាក់ព័ន្ធនឹងវិធីសាស្ត្របង្រៀនបញ្ច្រាស់ដោយប្រើបច្ចេកវិទ្យាព័ត៌មាន សម្រាប់សិស្សមួយចំនួនដែលមិនសូវចេះបច្ចេកវិទ្យាអាចមិនគាំទ្រវិធីសាស្ត្រនេះ ហើយបញ្ហាមួយទៀតគឺល្បឿនអ៊ីនធើណេតយឺតអាចបង្អាក់សិស្សមួយចំនួនដើម្បីមើលឬមើលមេរៀនជាវីដេអូឡើងវិញដោយរលូន និងបង្ខំឱ្យពួកគេរំលងផ្នែកខ្លះនៃមេរៀនផងដែរ។

ជាងនេះទៀតដោយការផ្លាស់ប្តូរទៅរកវិធីសាស្ត្របញ្ច្រាស់ជាបរិស្ថានរៀនសូត្រថ្មីមួយ សិស្ស/និស្សិតត្រូវការពេលវេលាគ្រប់គ្រាន់ដើម្បីសម្របជាមួយវិធីសាស្ត្រថ្មីបែបនេះ ជាពិសេសនៅក្នុងតំបន់អាស៊ីដែលសិស្ស/និស្សិតមានទម្លាប់ទៅនឹងការរៀនបែបអសកម្មចំពោះការស្តាប់ឧទ្ទេសនោះ ដូច្នេះពួកគេអាចមិនទាន់ស៊ាំនឹងបរិស្ថានរៀនសូត្រដែលសកម្មនិងដោយស្វយ័តទេ (Lee & Wallace, 2018)។ សម្រាប់គ្រូបង្រៀនដែលចង់ធ្វើការបង្រៀនបញ្ច្រាស់នៅក្នុងថ្នាក់រៀនវិញ ពួកគាត់គួរឆ្លុះបញ្ចាំងនូវបីចំណុច៖ ទីមួយដើម្បីអនុវត្តគំរូបង្រៀនបញ្ច្រាស់នេះគ្រូបង្រៀនត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យកម្មវិធីសិក្សារបស់ពួកគេនិងសម្រេចចិត្តលើទម្រង់សម្ភារៈបង្រៀននិងលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ និងទីពីរការបង្រៀនតាមអនឡាញគួរបញ្ចូលជាតុបង្គអន្តរកម្មផ្សេងៗជាពិសេសសម្រាប់វីដេអូជាបទបង្ហាញ និង ទីបីគ្រូបង្រៀនអាចពិចារណាការរៀបចំឬបម្រុងកន្លែងនៅបន្ទប់កុំព្យូទ័រ ដែលសិស្សអាចសិក្សាពីឯកសារបង្រៀនដោយមិនមានបញ្ហាអ៊ីនធើណេត ឬអាចជំនួសឯកសាររៀនតាមអនឡាញទៅជាការបោះពុម្ពឯកសារទុកឱ្យសិស្សអានជាមុនប្រសិនជាមានបញ្ហាអ៊ីនធើណេត (Lee & Wallace, 2018)។

ទាក់ទិននឹងបញ្ហាប្រឈមក្នុងការប្រើវិធីសាស្ត្របង្រៀនបញ្ច្រាស់សម្រាប់គ្រូបង្រៀនភាសាអង់គ្លេស Hashim & Shaari (2020) ដែលបានធ្វើការសិក្សាលើគ្រូបង្រៀនថ្នាក់បឋមនិងអនុវិទ្យាល័យជនជាតិម៉ាឡេស៊ីចំនួន ៥០នាក់ លទ្ធផលបានបង្ហាញថាគ្រូបង្រៀនជឿជាក់ថាសិស្សមិនចូលចិត្តការមើលវីដេអូ សិស្សមិនចាប់អារម្មណ៍នឹងសម្ភារៈអប់រំនៅក្នុងវិធីសាស្ត្របង្រៀនបញ្ច្រាស់ វិធីសាស្ត្របង្រៀនបញ្ច្រាស់ជាការខ្ជះខ្ជាយពេលវេលា គ្រូបង្រៀនមិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដែលរារាំងពួកគាត់ដើម្បីប្រើប្រាស់វិធីសាស្ត្រនេះ ព្រមទាំងទស្សនៈអវិជ្ជមានរបស់រដ្ឋបាលសាលានិងសហការីអំពីបច្ចេកវិទ្យាព័ត៌មានដែលបង្អាក់គ្រូបង្រៀនដើម្បីប្រើប្រាស់វិធីសាស្ត្របង្រៀនបញ្ច្រាស់។

## ៤. សេចក្តីសន្និដ្ឋាន

តាមរយៈការធ្វើសំយោគបណ្ណាល័យសាស្ត្រលើអត្ថបទទាំងឡាយខាងលើ អំពីផលប៉ះពាល់ទាំងវិជ្ជមាននិងអវិជ្ជមានពាក់ព័ន្ធនឹងការអនុវត្តវិធីសាស្ត្របង្រៀនបញ្ច្រាស់ បានបង្ហាញពីមតិវិជ្ជមានក្នុងទស្សនៈទាំងរបស់គ្រូបង្រៀននិងសិស្សានុសិស្សច្រើនជាងមតិអវិជ្ជមាន និងបានយល់ថាវិធីសាស្ត្រនេះបានជួយដំណើរការបង្រៀននិងការរៀនដោយសារវាបានលើកកម្ពស់ការរៀនជាលក្ខណៈបុគ្គល ការរៀនដោយសកម្ម មានភាពបត់បែន និងផ្តល់ឱកាសពិភាក្សាបានច្រើននិងការគ្រប់គ្រប់ពេលវេលាបានល្អប្រសើរ។ ទោះបីជាមានផលវិជ្ជមានច្រើនយ៉ាងណាក្តី វិធីសាស្ត្របង្រៀនបញ្ច្រាស់ក៏បង្កបញ្ហាប្រឈមពាក់ព័ន្ធនឹងតម្រូវការបច្ចេកវិទ្យា ទំនួលខុសត្រូវខ្ពស់របស់សិស្ស និងពេលវេលារៀបចំមេរៀនរបស់គ្រូបង្រៀន។ ដើម្បីអនុវត្តវិធីសាស្ត្រនេះបាន គ្រូបង្រៀននិងសិស្សានុសិស្សត្រូវជំនះបញ្ហាប្រឈមដែលបានរៀបរាប់ខាងលើក្នុងផ្នែក៣.២ រួមមានគ្រូបង្រៀននិងសិស្សគួរចេះប្រើបច្ចេកវិទ្យា ត្រូវលើកកម្ពស់ខ្លួនឯងដើម្បីអាចអនុវត្តវិធីសាស្ត្របង្រៀនបញ្ច្រាស់នៅក្នុងដំណើរការបង្រៀននិងរៀន។ យ៉ាងណាមិញវិធីសាស្ត្របង្រៀនបញ្ច្រាស់ជាវិធីសាស្ត្របង្រៀននិងរៀនដ៏ទំនើបមួយនេះដែលអាចកសាងសមត្ថភាពរៀនសូត្រដោយស្វយ័តភាព មិនទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយទេនៅក្នុងប្រព័ន្ធអប់រំប្រទេសកម្ពុជា។ យោងតាមការស្រាវជ្រាវខាងលើពាក់ព័ន្ធនឹងការបង្រៀននិងរៀនភាសាអង់គ្លេសជាភាសាបរទេស វិធីសាស្ត្របង្រៀនបញ្ច្រាស់ជាវិធីសាស្ត្រមួយប្រកបដោយប្រសិទ្ធភាពនិងគួរត្រូវបានអនុវត្តនៅក្នុងគ្រឹះស្ថានអប់រំទាំងឡាយនៅក្នុងប្រទេសកម្ពុជា។

ដូច្នេះការធ្វើសំយោគបណ្ណាល័យសាស្ត្រនេះរំពឹងទុកថា នឹងផ្តល់ជាសេចក្តីណែនាំដល់អ្នកស្រាវជ្រាវផ្សេងៗទៀតនាពេលអនាគត ដែលមានបំណងធ្វើការសិក្សាអំពីវិធីសាស្ត្របង្រៀនបញ្ច្រាស់ក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស។ លើសពីនេះទៀតអ្នកអប់រំដែលមានបំណងផ្លាស់ប្តូរវិធីសាស្ត្របង្រៀនពីបែបប្រពៃណីទៅវិធីសាស្ត្របង្រៀន បញ្ច្រាស់ គួរប្រមូលព័ត៌មានពីការសិក្សាស្តីពីគុណសម្បត្តិនិងគុណវិបត្តិរបស់វិធីសាស្ត្របង្រៀនបញ្ច្រាស់ក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស មុននឹងចាប់ផ្តើមអនុវត្តគំរូវិធីសាស្ត្របង្រៀនបញ្ច្រាស់ ដែលមានសក្តានុពលផ្លាស់ប្តូរបទពិសោធន៍ការបង្រៀននិងការរៀនសូត្រក្នុងសតវត្សរ៍ទី២១នេះ។

## ឯកសារយោង


Abdullah, M. Y., Hussin, S., Hammad, Z. M., & Ismail, K. (2021). Exploring the effects of flipped classroom model implementation on EFL learners′ self-confidence in English speaking performance. *recent advances in intelligent systems and smart applications*, 223-241.

Abedi, P., Keshmirshekan, M. H., & Namaziandost, E. (2019). The comparative effect of flipped classroom instruction versus traditional instruction on Iranian intermediate EFL learners' English composition writing. *Journal of Applied Linguistics and Language Research*, *6*(4), 43-56.

Alghasab, M. B. (2020). Flipping the writing classroom: Focusing on the pedagogical benefits and EFL leaners′ perceptions. *English Language Teaching*, *13*(4), 28-40. doi:10.5539/elt.v13n4p28

Alsowat, H. (2016). An EFL flipped classroom teaching model: Effects on English language higher-order thinking skills, student engagement and satisfaction. *Journal of Education and Practice*, *7*(9), 108-121.

Ansori, M., & Nafi, N. N. (2018). English teachers' perceived benefits and challenges of flipped classroom implementation. *JEELS*, *5*(2), 211-226. doi:10.30762/jeels.v5i2.820.

Bergmann, J., & Sams, A. (2012). Flip your classroom: Reach every student in every class every day*.* Arlington: International Society for Technology in Education.

Bergmann, J. & Sams, A. (2014). *Flipped Learning: Gateway to Student Engagement.* Washington DC: International Society for Technology in Education.

Birová, L. (2019). Flipped classroom and its use in teaching English as a foreign language. *Publicaciones: Facultad de Educación y Humanidades del Campus de Melilla*, *49*(5), 93-112.

Chen Hsieh, J. S., Wu, W. C. V., & Marek, M. W. (2017). Using the flipped classroom to enhance EFL learning. *Computer Assisted Language Learning*, *30*(1-2), 1-21.

Deng, F. (2019). Literature review of the flipped classroom . *Theory and Practice in Language Studies, 9* (10), 1350-1356.

Doman, E., & Webb, M. (2017). The flipped experience for Chinese university students studying English as a foreign language. *TESOL Journal*, *8*(1), 102-141. doi: 10.1002/tesj.264.

Dunn, J. (2014). The 6-step guide to flipping your classroom. Retrieved from https://medium.com/@jdunns4/the-6-step-guide-to-flipping-your-classroom-d721878f85c1

Fauzan, A., & Ngabut, M. N. (2018). EFL students' perception on flipped learning in writing class*.* *Journal on English as a Foreign Language*, *8*(2), 115-129. doi: 10.23971/jefl.v8i2.792.

Fielden, L. V., Rico, M., & Naranjo, M. J. (2020). Flipped classrooms: Making them work for foreign language students. *34* (1), 336-354. DOI: doi.org/10.21814/diacritica.286

Hashim, N. A., & Shaari, N. D. (2020). Malaysian teachers' perception and challenges towards the implementation of flipped learning approach. *Asian People Journal (APJ)*, *3*(2), 62-76.

Lee, G., & Wallace, A. (2018). Flipped learning in the English as a foreign language classroom: Outcomes and perceptions. *TESOL quarterly*, *52*(1), 62-84.

Kırmızı, Ö., &Kömeç, F. (2019). The impact of the flipped classroom on receptive and productive vocabulary learning. *Journal of Language and Linguistic Studies, 15*(2), 437-449.

Mahalli, N. J., Mujiyanto, J., & Yuliasri, I. (2019). The implementation of station rotation and flipped classroom models of blended learning in EFL learning. *English Language Teaching*, *12*(12), 23-29. doi: 10.5539/elt.v12n12p23.

Martin, M. (2022). What's a flipped classroom and why should I use one? Retrieved from https://www.thinkific.com/blog/flipped-classroom/

Mehta, S. (2023). Modern teaching methods – It's time for the change. Retrieved from https://eduvoice.in/modern-teaching-methods/

Michigan State University (n.d). What, why, and how to implement a flipped classroom model. Assessed on 4 July 2023 from https://omerad.msu.edu/teaching/teaching-skills-strategies/27-teaching/162-what-why-and-how-to-implement-a-flipped-classroom-model

Mulawarman, M., Susilawati, S., Syifa, L., & Rifani, E. (2020). Classroom guidance strategy with flipped method in guidance and counseling services at Indonesia schools in the digital era. *Islamic Guidance and Counseling Journal*, *3*(2), 61-74.

Ngo, H. K., & Yunus, M. (2021). Flipped classroom in English language teaching and learning: A systematic literature review. *International Journal of Academic Research in Business and Social Sciences*, *11*(3), 185-196.

Nuon, P., & Champakaew, W. (2017). Effects of ICT-aided flipped classroom on grammar achievement. In *International Conference on Language, Education, Humanities and Innovation 5th & 6th August*.

Phoeun, M., & Sengsri, S. (2021). The Effect of a flipped classroom with communicative language teaching approach on undergraduate students' English speaking ability. *International Journal of Instruction*, *14*(3), 1025-1042.

Renxian, Z. (2014). Flipping classroom model and teaching transition. Beijing: World Knowledge Press.

Roth, C., & Suppasetseree, S. (2016). Flipped classroom: can it enhance English listening comprehension for pre-university students in Cambodia. *Proceedings of classic: Learning in and beyond the classroom: Ubiquity in foreign language education*, 255-264.

The Four Pillars of Flipped Learning (2017). Retrieved from https://study.com/academy/lesson/the-four-pillars-of-flipped-learning.html.

Yang, R. C. C., & Chen, Y. Y. (2020). Implementing the flipped classroom approach in primary English classrooms in China. *Education and Information Technologies*, *25*(2), 1217-1235. doi: 10.1007/s10639-019-10012-6.